# វេយ្យាករណ៍គន្លឹះ

## អំពី

## ស្វរព្យញ្ជនៈ និងស្រៈខ្មែរ

# ស្វែងយល់អំពីគ្នា

- ឈ្មោះ
- មកពី(អង្គភាព)
- តួនាទី
- អតីតភាព

យើងឯកភាពគ្នាដូចខាងក្រោម៖

- យើងពិភាក្សាដើម្បីរៀនជាមួយគ្នា
- យើងគោរពគ្នា
- យើងការពារកុមារ

SeeBeyondBorders

# តើអ្នកពន្យល់សិស្សដូចម្ដេចចំពោះចំណុចដែលថា .. ព្យញ្ជនៈខ្មែរមានសញ្ញាច្រើនជាងស្រៈ?







SeeBeyondBorders

# យើងនឹងសិក្សាជាមួយគ្នា!

- មានសៀវភៅបោះពុម្ពផ្លូវការជាច្រើន មានលក់នៅលើទីផ្សារ
- បទសម្ភាសន៍ជាមួយអ្នកជំនាញ និងចែកផ្សាយលើInternet
- យល់ព្រមដោយរដ្ឋមន្ត្រីអប់រំ



# សៀវភៅវេយ្យាករណ៍ បណ្ឌិត នៅ ស៊ុន (២០១៣)
# ទាញយកពីបណ្ណាល័យអេឡិចត្រូនិចខ្មែរ, 2024

- ស្របតាមកម្មវិធីសិក្សាថ្មីរបស់ក្រសួងអប់រំ
- សៀវភៅនេះនឹងផ្តល់ផលប្រយោជន៍ច្រើនចំពោះមាតាបិតាគ្រូបង្រៀនក្នុងការ<u>បង្រៀនកុមារឱ្យចេះអាន ចេះសរសេរគ្រប់គ្នាបានត្រឹមត្រូវស្របតាមក្បួនវេយ្យាករណ៍</u>



## អារម្ភកថា

សៀវភៅវេយ្យាករណ៍ថ្មីនេះ ភាគច្រើនដកស្រង់ចេញពីសៀវភៅភាសាខ្មែរមធ្យមសិក្សាដែលស្របតាមកម្មវិធីសិក្សាថ្មីរបស់ ក្រសួងអប់រំ យុវជន និងកីឡា ដោយមានបន្ថែមចំណុចខ្លះៗទៅលើនិយមន័យនិងការពន្យល់បញ្ញត្តិនានា ហើយទន្ទឹមនឹងនេះដែរ មានការបញ្ចេញទស្សនៈផ្ទាល់ខ្លួនទៅលើចំណុចមួយចំនួន ដែលអ្នករៀបរៀងយល់ថានៅមានភាពមិនទាន់ច្បាស់លះ ឬភាពប្រទាំងប្រទើសនៅឡើយ ។ សៀវភៅនេះនឹងជួយអ្នកសិក្សា ជាពិសេសសិស្សានុសិស្សឱ្យងាយស្រួលក្នុងការបើកមើល ដោយមិនបាច់យកសៀវភៅសិក្សាគោលមកប្រើឡើយ ។

យើងខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងផ្តល់ផលប្រយោជន៍យ៉ាងច្រើនចំពោះមាតាបិតានិងអាណាព្យាបាលសិស្ស ក៏ដូចជាសាលារៀន គ្រូបង្រៀន ក្នុងការជួយ បង្រៀនកុមារឱ្យចេះអាន ចេះសរសេរគ្រប់គ្នាបានល្អត្រឹមត្រូវស្របតាមក្បួនវេយ្យាករណ៍ ហើយសិស្សអាចមានសមត្ថភាពរឹងមាំក្នុងការបន្តការសិក្សាទៅថ្នាក់បន្ទាប់ទៀតបានប្រកបដោយគុណភាពពិតប្រាកដ ។

តាមរយៈសៀវភៅនេះ យើងខ្ញុំសូមជូនពរអ្នកអានទទួលបានជោគជ័យក្នុងការសិក្សាវេយ្យាករណ៍ ដើម្បីពង្រឹងសមត្ថភាពផ្នែកភាសាខ្មែរ និងជួយឱ្យសតិបញ្ញា ស្មារតីប្អូនៗកាន់តែរីកចម្រើន ហើយយើងខ្ញុំក៏រង់ចាំការកែលំអផ្តល់យោបល់ពីអ្នកអាន ជាពិសេសពីសំណាក់លោកគ្រូ-អ្នកគ្រូដោយរីករាយផងដែរ ។

អរគុណ !

# ព្យញ្ជនៈខ្មែរ

- ក្នុងការបន្លឺសូរព្យញ្ជនៈណាមួយ គេនិយមយកស្រៈដែលមានសូរកញ្ជក់ខ្លីបំផុតមកផ្សំជាមួយ។
- ខ្មែរយើងច្រើនយកស្រៈ [ə] មកប្រើក្នុងការបន្លឺសូរព្យញ្ជនៈខ្មែរ។



ព្យញ្ជនៈ

និយមន័យ :

ព្យញ្ជនៈ គឺជាសូរដែលបន្លឺឡើងដោយមានទំនប់តិច ឬច្រើន អាស្រ័យទៅតាមរង្វះខ្យល់ ដែលចេញពីសួត ។ នៅពេលដែលខ្យល់ចេញពីសួតទៅប៉ះនឹងទំនប់រង្វះខ្យល់កម្រិតសូន្យ (០)បង្កើតបានជាព្យញ្ជនៈស្ទះ ឬផ្ទុះ ។ បើកាលណារង្វះខ្យល់មានកម្រិតលើសពីសូន្យ បង្កើតបានជាព្យញ្ជនៈត្រដុស បង្ហូរ ឬលំហូរ... ។ សូរព្យញ្ជនៈមិនអាចបន្លឺបានច្បាស់ទេ បើប្រសិនគ្មានសូរស្រៈនៅអាស្រ័យជាមួយ ។

ក្នុងការបន្លឺសូរព្យញ្ជនៈណានីមួយៗ គេនិយមយកស្រៈដែលមានសូរកញ្ជក់ខ្លីបំផុតមកផ្សំជាមួយ ។ ជាទូទៅ គេនិយមយកស្រៈ [ə] ឬស្រៈ [a] មកប្រើ ។ ខ្មែរយើងច្រើនយកស្រៈ [ə] មកប្រើក្នុងការបន្លឺសូរព្យញ្ជនៈខ្មែរ ដូចជា បន្លឺសូរ [k] យើងតែងតែថា [kə] [c] យើងតែងតែថា [cə] ជាដើម ។ បើបាលីគេនិយមយកស្រៈ [ a ] ដូចជា [ ka ] [ kha ] [ ca ] [ cha ] ជាដើម ។

ចំណាត់ថ្នាក់សូរព្យញ្ជនៈ

គេអាចចាត់ថ្នាក់សូរព្យញ្ជនៈទៅតាមលក្ខណៈ (របៀប) បន្លឺនិងទីបន្លឺ ៖

ក. ចំណាត់ថ្នាក់សូរព្យញ្ជនៈតាមលក្ខណៈបន្លឺ

តាមលក្ខណៈបន្លឺ គេចែកសូរសំខាន់ៗនៃព្យញ្ជនៈខ្មែរជាបួនយ៉ាង គឺ ព្យញ្ជនៈស្ទះ ព្យញ្ជនៈបង្ហូរ លំហូរ ព្យញ្ជនៈត្រដុស ព្យញ្ជនៈមាត់ និងព្យញ្ជនៈច្រមុះ ។

# ព្យញ្ជនៈខ្មែរ

## សរុបសញ្ញាព្យញ្ជនៈ= ៩០

## សរុបសូរ =២០

បើគិតទាំងសញ្ញាមូលដ្ឋាន និងសញ្ញាបន្ថែម (ក្នុងនោះមានជើងព្យញ្ជនៈនិងសញ្ញាបន្ទាប់បន្សំដទៃទៀត) សញ្ញាព្យញ្ជនៈខ្មែរកើនដល់ ៩៤(នេះបើរាប់ទាំងក្រុមសញ្ញា "អ" ផង) តែបើមិនរាប់បញ្ចូលក្រុមសញ្ញា "អ"ដោយគិតថា "អ"ជាសញ្ញាស្រៈនោះព្យញ្ជនៈខ្មែរមានសញ្ញា ៩០តួ។

តារាងទី ៤ : តួព្យញ្ជនៈនិងសូរព្យញ្ជនៈក្នុងភាសាខ្មែរ

| លេខរៀង | តួព្យញ្ជនៈ | ចំនួនតួ | សូរព្យញ្ជនៈ | ចំនួនសូរ |
|---|---|---|---|---|
| ១ | ក ្ក គ ្គ | ៤ | [k] | ១ |
| ២ | ខ ្ខ ឃ ្ឃ | ៤ | [kh]* | ១ |
| ៣ | ង ្ង ង៉ ងុ | ៤ | [ŋ] | ១ |
| ៤ | ច ្ច ជ ្ជ | ៤ | [c] | ១ |
| ៥ | ឆ ្ឆ ឈ ្ឈ | ៤ | [ch]* | ១ |
| ៦ | ញ ្ញ ្ញ ញា ញ៉ ញុ | ៦ | [ɲ] | ១ |
| ៧ | ដ ្ដ ឌ ្ឌ | ៤ | [d] | ១ |
| ៨ | ត ្ត ទ ្ទ | ៤ | [t] | ១ |
| ៩ | ឋ ្ឋ ឍ ្ឍ ថ ្ថ ធ ្ធ | ៨ | [th]* | ១ |
| ១០ | ណ ្ណ ន ្ន ន៉ នុ | ៦ | [n] | ១ |
| ១១ | ប ្ប ប៊ | ៣ | [b] | ១ |
| ១២ | ប៉ បុ ព ្ព ្ព | ៥ | [p] | ១ |
| ១៣ | ផ ្ផ ភ ្ភ | ៤ | [ph]* | ១ |
| ១៤ | ម ្ម ម៉ មុ ំ | ៥ | [m] | ១ |
| ១៥ | យ ្យ យ៉ យុ | ៤ | [j] | ១ |
| ១៦ | រ ្រ រ៉ រុ | ៤ | [r] | ១ |
| ១៧ | ល ្ល ល៉ លុ ឡ | ៥ | [l] | ១ |
| ១៨ | វ ្វ វ៉ វុ | ៤ | [v] | ១ |
| ១៩ | ស ្ស ស៊ សុ | ៤ | [s] | ១ |
| ២០ | ហ ្ហ ហ៊ ហុ | ៤ | [h] | ១ |
| | សរុបសញ្ញាព្យញ្ជនៈ | ៩០ | សរុបសូរ | ២០ |



សូរដែលមានដាក់សញ្ញា "*" នៅខាងក្រោយអ្នករៀបរៀងសៀវភៅនេះមិនចាត់ទុកជាសទ្ទតាព្យញ្ជនៈទេ តែជាសូរព្យញ្ជនៈផ្សំ ថ្វីត្បិតតែមានសញ្ញា ដូចជាព្យញ្ជនៈទោលក៏ដោយ។

បើនិយាយពីសូរព្យញ្ជនៈវិញនោះ គេមិនទាន់កំណត់ឱ្យមានឯកភាពនៅឡើយទេ បានន័យថា ការកំណត់នេះស្ថិតនៅលើទស្សនៈអ្នកសិក្សាស្រាវជ្រាវម្នាក់ៗ ក្រុមៗនៅឡើយ។ អ្នកសិក្សាស្រាវជ្រាវមួយក្រុមធំកំណត់ថា សូរព្យញ្ជនៈខ្មែរមាន ២១គឺ [k] [kh] [ŋ] [c] [ch] [ɲ] [d] [t] [th] [n] [b] [p] [ph] [m] [j] [r] [l] [v] [s] [h] និង [ʔ]។ អ្នកសិក្សាស្រាវជ្រាវមួយក្រុមទៀតកំណត់ថាសូរព្យញ្ជនៈខ្មែរមាន 20 សូរ ដោយមិនចាត់ទុកថា [ʔ] ស្ថិតក្នុងប្រព័ន្ធសូរព្យញ្ជនៈខ្មែរ (កេង វ៉ាន់សាក់ ឃួន សុគន្ធ) អ្នកស្រាវជ្រាវមួយក្រុមទៀតកំណត់សូរព្យញ្ជនៈខ្មែរថាមាន ១៧ ដោយដកសូរ [kh] [ch] [th] [ph] ចេញ ព្រោះលោក អ្នកទាំងនោះចាត់ទុកថាសូរទាំងបួននេះជាសូរផ្សំ [kh] = [k+h] [ch] = [c+h] [th] = [t+h] [ph] =

# អំពីស្រៈ




- ស្រៈជាសទ្ទតាមួយប្រភេទដែលគ្មានទំនប់អ្វីមួយរារាំងក្នុងការបន្លឺ
- ភាសាខ្មែរមានសូរស្រៈច្រើន គឺលើសពី ៣០
- ស្រៈជាអក្សរដែលអាចបញ្ចេញសំឡេងខ្លួនឯងបានផង អាចនាំព្យញ្ជនៈឱ្យចេញសំឡេងបានមានសូរឮតាមរំពងរបស់ព្យញ្ជនៈផង (សម្តេចសង្ឃរាជ ជួន ណាត ១៩៦៨ ទំព័រ១៤៦២)

# សូរព្យាង្គ



# ព្យាង្គ

និយមន័យ :

ក្នុងន័យទូទៅព្យាង្គ គឺជាបណ្តុំនៃព្យញ្ជនៈនិងស្រៈដែលបន្លឺឡើងតែមួយបន្ទាយសំឡេង[1] ។

តាមបែបភាសាវិទ្យាព្យាង្គ គឺជារចនាសម្ព័ន្ធគ្រឹះ ដែលជាមូលដ្ឋាននៃការផ្តុំសទ្ទតាទាំងឡាយនៅក្នុងចរន្តសំដី ។ រចនាសម្ព័ន្ធនេះឈរលើគ្រឹះនៃភាពប្រឈមនៃសទ្ទតាទាំងឡាយដែលតាមទម្លាប់គេហៅថាជា "ស្រៈ" និង "ព្យញ្ជនៈ" ។

ក្នុងន័យនេះ ព្យាង្គ គឺជាឯកតាសូរវិទ្យានិងសទ្ទតាវិទ្យាដែលកើតឡើងដោយសារបណ្តុំសទ្ទតាស្រៈនិងសទ្ទតាព្យញ្ជនៈដែលបន្លឺឡើងក្នុងមួយបន្ទាយសំឡេង ។

ដូច្នេះ ព្យាង្គទាក់ទងជាមួយនឹងសូរ មិនទាក់ទងនឹងសំណេរឡើយ ។

## ១. ធាតុរបស់ព្យាង្គ

ជាទូទៅ ព្យាង្គមានធាតុបីសំខាន់ៗគឺ ព្យញ្ជនៈដើមព្យាង្គ ស្រៈកណ្តាលព្យាង្គ ឬណ្វៃយ៉ូព្យាង្គ និងព្យញ្ជនៈចុងព្យាង្គ ។

ជាទូទៅព្យញ្ជនៈដើមព្យាង្គអាចជាព្យញ្ជនៈទោលនិងអាចជាបន្សំព្យញ្ជនៈ (សម្រាប់ភាសាខ្មែរ បន្សំព្យញ្ជនៈមិនលើសពីពីរសូរឡើយ ។

ស្រៈកណ្តាលព្យាង្គ ឬណ្វៃយ៉ូជាធាតុសំខាន់សម្រាប់បង្កើតព្យាង្គ បានន័យថា គ្មានព្យាង្គណាមួយដែលអាចកើតឡើងដោយគ្មានស្រៈកណ្តាល ឬ

1. Groupe formé de consonnes et de voyelles qui se prononcent d'une seule émission du voix ( Dictionaire encyclopédique larousse,1979, p1357 )

៣២

- ព្យាង្គទាក់ទងជាមួយសូរ មិនទាក់ទងនឹងសំណេរឡើយ
- ព្យញ្ជនៈដើមព្យាង្គមានសូរផ្ទុះ
- ព្យញ្ជនៈចុងព្យាង្គមានសូរលេប

SeeBeyondBorders

# ក- ឬ ក?

## ផ្ទត់ដើមទម្រង់ ព-



### កម្លាយដោយផ្ទត់ដើម

នៅក្នុងភាសាខ្មែរ មានវិធីបង្កើតពាក្យច្រើនបែបច្រើនយ៉ាង ។ បង្កើតពាក្យតាមកម្លាយដោយផ្ទត់ដើម គឺគេយកផ្ទត់ដើមទៅដាក់ជាប់ ពាក្យឬស ។

. ផ្ទត់ដើមទម្រង់ ព- កើតមកពីព្យញ្ជនៈទោលតែមួយប៉ុណ្ណោះ ។

- ផ្ទត់ដើម [ក-] [ k- ]
  - [ក-] + ម៉ៅ > ខ្មៅ [ k- ] + [ mau ] > [ kma
  - [ក-] + ជាប់ > ខ្ជាប់ [ k- ] + [ coa:p ] > [ kcoa
- ផ្ទត់ដើម [ច-] [ c- ]
  - [ច-] + បង > ច្បង [ c- ] + [ bɒ:ŋ ] > [ cbɒ:
  - [ច-] + រាល > ច្រាល [ c- ] + [ rea:l ] > [ crea
- ផ្ទត់ដើម [ជ-] [ c- ]
  - [ជ-] + រុះ > ជ្រុះ [ c- ] + [ ruh ] > [ cruh ]
  - [ជ-] + រុល > ជ្រុល [ c- ] + [ rul ] > [ crul ]
- ផ្ទត់ដើម [ត-] [ t- ]
  - [ត-] + រិះ > ត្រិះ [ t- ] + [ rih ] > [ trẹh ]
  - [ត-] + មោង > ត្មោង [ t- ] + [ mo:ŋ ] > [ tmao
- ផ្ទត់ដើម [ទ-] [ t- ]
  - [ទ-] + រេល > ទ្រេល [ t- ] + [ re:l ] > [ tre:l
  - [ទ-] + រឹង > ទ្រឹង [ t- ] + [ rɯŋ ] > [ trɯ

## ផ្ទត់ដើមទម្រង់ ព.ស-



- ផ្ទត់ដើម [ប៉-] [ p- ]
  - [ប៉-] + ដឹង > ប្ដឹង [ p- ] + [ dœŋ ] > [ pdœŋ ]
  - [ប៉-] + ដាច់ > ផ្ដាច់ [ p- ] + [ dac ] > [ pdac ]
- ផ្ទត់ដើម [ម-] [ m- ]
  - [ម-] + ង៉ក់ > ម្ង៉ក់ [ m- ] + [ ŋɒʔ ] > [ mŋɒʔ ]
  - [ម-] + ជូរ > ម្ជូរ [ m- ] + [ cu: ] > [ mcu: ]
- ផ្ទត់ដើម [ស-] [ s- ]
  - [ស-] + កក > ស្កក [ s- ] + [ kɒ:ʔ ] > [ skɒ:ʔ ]
  - [ស-] + គាល់ > ស្គាល់ [ s- ] + [ koa:l ] > [ skoa:l ] ។

. ផ្ទត់ដើមទម្រង់ ព.ស- ប្រើសម្រាប់បង្កើតពាក្យពីរព្យាង្គ ។

- ផ្ទត់ដើម [ក-] [ kɒ:- ]
  - [ក-] + កាយ > កកាយ [ kɒ:- ] + [ ka:j ] > [ kɒka:j ]
  - [ក-] + ក្អាក > កក្អាក [ kɒ:- ] + [kʔa:ʔ] > [kɒkʔa:ʔ]
- ផ្ទត់ដើម [ច-] [ cɒ:- ]
  - [ច-] + ចឹក > ចចឹក [ cɒ:- ] + [ coek ] > [ cɒcœk ]
  - [ច-] + ចាក់ > ចចាក់ [ cɒ:- ] + [ caʔ ] > [ cɒcaʔ ]
- ផ្ទត់ដើម [ត-] [ tɒ:- ]
  - [ត-] + តះ > តតះ [ tɒ:- ] + [ tah ] > [ tɒtah ]
  - [ត-] + តោង > តតោង [ tɒ:- ] + [ tao:ŋ ] > [ tɒtao:ŋ ]
- ផ្ទត់ដើម [ស-] [ sɒ:- ]
  - [ស-] + សិត > សសិត [ sɒ:- ] + [ sœt ] > [ sɒsœt ]
  - [ស-] + សៀរ > សរសៀរ [ sɒ:- ] + [ si:e ] > [ sɒsi:e ]

៤៧

# ក- ឬ ក?

## ផ្នត់ដើមទម្រង់ ព-

- ផ្នត់ដើម [ក-] [k-]

[ក-] + ម៉ៅ> ខ្មៅ

- ផ្នត់ដើម [ម-] [m-]

[ម-] + ជូរ > ម្ជូរ

## ផ្នត់ដើមទម្រង់ ព.ស-

- ផ្នត់ដើម [ក-] [ᴋä]

[ក-] + កាយ > កកាយ

# សូមអរគុណ

បើមានសំណួរ សូមអញ្ជើញសួរ

